00332869

E43/4

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 26 / 05 / 2009
ម៉ោង (Time/Heure): 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: C.A. Fuy

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០១/១៨ កក្កដា ២០០៧-អវតក/អជសដ
**Case File/Dossier No. 001/18-07-2007-ECCC/TC**

ចំពោះមុខ: ចៅក្រម **និល ណុន** ជាប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម **យ៉ា សុខន**
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម **ធូ មណី**

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date /Date de certification): 27 / 05 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: C.A. Fuy

កាលបរិច្ឆេទ: ថ្ងៃទី ២៦ ខែឧសភា ឆ្នាំ២០០៩
ចំណាត់ថ្នាក់ឯកសារ សាធារណៈ:

## សេចក្តីសម្រេចស្តីពីភាពអាចទទួលយកសម្ភារៈដែលមាននៅក្នុងសំណុំរឿងធ្វើជាភស្តុតាង

**សហព្រះរាជអាជ្ញា**
ជាលាង
Robert PETIT

**ជនជាប់ចោទ**
កាំង ហ្គេកអ៊ាវ ហៅ ឌុច

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
គង់ ពិសី
ហុង គឹមសួន
យុង ផានិត
គីម ម៉េងឃី
ម៉ុច សុវណ្ណារី
Silke STUDZINSKY
Martine JACQUIN
Philippe CANONNE
ទី ស្រីនណា
Pierre Olivier SUR
Alain WERNER
Brianne McGONIGLE
Annie DELAHAIE
Elizabeth RABESANDRATANA
Karim KHAN

**មេធាវីជនជាប់ចោទ**
ការ សាវុត្ថ
François ROUX
Marie-Paule CANIZARES

E.C.C.C. TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE

ផ្លូវជាតិលេខ ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុងភ្នំពេញ កម្ពុជា ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ: (៨៥៥)-២៣-២១៨៩១៤ ទូរសារ: (៨៥៥)-២៣-២១៨៩៤១ គេហទំព័រ: www.eccc.gov.kh
National Road 4 ,Chaom Chau , Dangkao Phnom Penh Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax:023 218941 Web: www.eccc.gov.kh

00332870



E43/4

**អង្គជំនុំជម្រះសាលាដំបូង** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អ.វ.ត.ក”)

**ក្រោយពីបានទទួល** សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសង អនុលោមតាម “សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ដែលចោទប្រកាន់លើជនត្រូវចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច” ដែលប្រកាសផ្ទាល់មាត់ដោយអង្គបុរេជំនុំជម្រះ នៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨ និងបានដាក់សេចក្តីសម្រេចជាភាសាខ្មែរ នៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០០៨[1]។

**ក្រោយពីបានស្តាប់** សំណើរបស់មេធាវីការពារក្តី ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៩ សុំឱ្យអង្គជំនុំជម្រះសាលាដំបូងបដិសេធមិនទទួលយកឯកសារចំនួនបីធ្វើជាភស្តុតាង និងសុំឱ្យអង្គជំនុំជម្រះកម្រិតនូវការប្រើប្រាស់ឯកសារបន្ថែមមួយទៀតប្រឆាំងនឹងជនជាប់ចោទ (“សំណើ”)[2]។

**កត់សម្គាល់ឃើញ** សេចក្តីសន្និដ្ឋានផ្ទាល់មាត់ និងជាលាយលក្ខណ៍អក្សររបស់សហព្រះរាជអាជ្ញា និងរបស់ក្រុមដើមបណ្តឹងរដ្ឋប្បវេណី ដែលបានធ្វើកាលពីថ្ងៃទី៧ និងទី២២ ខែមេសា ឆ្នាំ២០០៩ និងបានដាក់កាលពីថ្ងៃទី៧ និងទី៨ ខែមេសា ឆ្នាំ២០០៩ ដែលជំទាស់ទៅនឹងសំណើ[3]។

---

[1] “សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណីរបស់ កាំង ហ្កេកអ៊ាវ ហៅ ឌុច” ថ្ងៃទី ០៥ ខែធ្នូ ឆ្នាំ២០០៨ (ឯកសារ D99/3/42)។

[2] ប្រតិចារឹក (“T”) ថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៩ ទំព័រ 35។ T., ថ្ងៃទី៦ ខែមេសា ឆ្នាំ២០០៩ ទំព័រ9, 12-13។

[3] T., ថ្ងៃទី៦ ខែមេសា ឆ្នាំ២០០៩, ទំព័រ10-12; T., ថ្ងៃទី៧ ខែមេសា ឆ្នាំ២០០៩, ទំព័រ46, 53-55។ T., ថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៩, ទំព័រ8-12, 16-31។ “ការស៊ើបអង្កេតរបស់សហព្រះរាជអាជ្ញាស្តីពីការតទល់គ្នារបស់ជនជាប់ចោទទៅនឹងកំណត់ហេតុបទសម្ភាសន៍របស់ UNHCHR” ឯកសារលេខ E43/3 ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩។ “ការអង្កេតរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី (ក្រុម៣) ពាក់ព័ន្ធនឹងកិច្ចសម្ភាសន៍ជនជាប់ចោទ M. Peschoux” ឯកសារលេខ E43 ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៩ ។ “ក្រុម១ - សំណើសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំបដិសេធការហាមមិនឱ្យផ្សព្វផ្សាយបទសម្ភាសន៍របស់ Christophe Peschoux” ឯកសារលេខE43/1 ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩។ “សំណើរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីស្តីពីការប្រើប្រាស់បទសម្ភាសន៍របស់ជនជាប់ចោទជាមួយអ្នកតំណាង UNHCHR និងអ្នកសារព័ត៌មាន” ឯកសារលេខ E43/2 ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩។



TRIAL CHAMBER CHAMBRE DE PREMIERE INSTANCE E C C C

**ក្រោយពីបានស្តាប់** សំណើផ្ទាល់មាត់របស់សហព្រះរាជអាជ្ញា កាលពីថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៩ សុំអនុញ្ញាតប្រើប្រាស់ឯកសារបន្ថែមមួយនៅចំពោះមុខអង្គជំនុំជម្រះ និងកត់សម្គាល់ឃើញថា សហមេធាវីការពារក្តីមិនបានជំទាស់ទៅនឹងសំណើនេះទេ[4]។

**អាស្រ័យហេតុនេះ សម្រេចដូចខាងក្រោម:**

## ក. សេចក្តីផ្តើម

១. សេចក្តីសម្រេចនេះសរុបរួមនូវសំណើសុំដោយផ្ទាល់មាត់ និងជាលាយលក្ខណ៍អក្សរ ដែលពាក់ព័ន្ធនឹងការប្រើប្រាស់ធ្វើជាភស្តុតាងនូវឯកសារដូចខាងក្រោម នៅក្នុងសវនាការនេះ :

ក. ចម្លើយរបស់សាក្សីដែលបានទទួលមរណភាពពីរនាក់ ដែលបានកត់ត្រាដោយតំណាងមជ្ឈមណ្ឌលឯកសារកម្ពុជាដែលជាអង្គការក្រៅរដ្ឋាភិបាល ("DC-Cam") ដែលចម្លើយនោះ ត្រូវបានដាក់បញ្ចូលនៅក្នុងសំណុំរឿងជាឯកសារ D59.4 និង D59.12[5]។

ខ. ចម្លើយរបស់ជនជាប់ចោទ ដែលបានកត់ត្រានៅក្នុងខែឧសភា ឆ្នាំ១៩៩៩ ដោយតំណាងឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ (UNHCHR) ដែលចម្លើយនោះត្រូវបានដាក់បញ្ចូលនៅក្នុងសំណុំរឿងជាឯកសារ D9[6] និង

គ. ឯកសារដែលអះអាងថាជាកំណត់ហេតុនៃការសួរចម្លើយរបស់ ឈឹន សុទ្ធី ដែលបានធ្វើកាលពីថ្ងៃទី២២ ខែមករា ឆ្នាំ១៩៧៥ ("របាយការណ៍លេខ ៦៤/៧៥/០៨ លេខបោះពុម្ពផ្សាយ ១៨") ដែលឯកសារនោះត្រូវបានដាក់បញ្ចូលនៅក្នុងសំណុំ

[4] T., ថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៩ ទំព័រ3, 15-16។

[5] ឯកសារ D59, ឧបសម្ព័ន្ធ៤ និង D59, ឧបសម្ព័ន្ធ12 ("ចម្លើយរបស់សាក្សីដែលបានទទួលមរណៈភាព")។

[6] ឯកសារ D9 ("បទសម្ភាសន៍របស់ UNHCHR")

រឿងជាឯកសារលេខ ១៩.២៥ (ឧបសម្ព័ន្ធ គ នៃសេចក្ដីសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ)[7]។

## ខ. សារណា

២. មេធាវីការពារក្ដី បានជំទាស់ទៅនឹងការប្រើប្រាស់ចម្លើយរបស់សាក្សីដែលបានទទួលមរណភាពពីរនាក់របស់អង្គជំនុំជម្រះដោយហេតុថាចម្លើយទាំងនេះមិនមែនជាឯកសារស្របច្បាប់នោះទេ ប៉ុន្តែផ្ទុយទៅវិញគ្រាន់តែជាចម្លើយដែលធ្វើឡើងដោយមិនបានស្បថដែលកត់ត្រាដោយ តំណាងអង្គការក្រៅរដ្ឋាភិបាល។ អង្គជំនុំជម្រះសាលាដំបូងត្រូវកម្រិតនូវភាពជឿជាក់លើសក្ខីកម្មរបស់សាក្សី ចំពោះសាក្សីទាំងឡាយណាដែលអាចបង្ហាញខ្លួននៅក្នុងតុលាការបាន។ សហមេធាវីការពារក្ដីបដិសេធទៅនឹងការប្រើប្រាស់កំណត់ហេតុរបស់ឧត្ដមស្នងការទទួលបន្ទុកសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ដោយសារតែរបៀបក្នុងការសួរយកចម្លើយនោះ និងជាពិសេសនៅមុនពេលដែលត្រូវគេសួរយកចម្លើយជនជាប់ចោទមិនត្រូវបានគេប្រាប់អំពីសិទ្ធិរបស់គាត់ក្នុងការនៅស្ងៀមមិនឆ្លើយតបនោះទេ[8]។

៣. នៅក្នុងការឆ្លើយតប សហព្រះរាជអាជ្ញាដែលគាំទ្រដោយដើមបណ្ដឹងរដ្ឋប្បវេណី លើកឡើងថា រាល់ឯកសារទាំងអស់អាចទទួលយកបាន ស្របតាមវិធាន ៨៧(១) នៃវិធានផ្ទៃក្នុង។ នៅក្នុងវិធានផ្ទៃក្នុង មិនមានមូលដ្ឋានណាមួយសម្រាប់បដិសេធចម្លើយរបស់សាក្សីដែលទទួលមរណភាពនោះទេ ហើយក៏មិនមានមូលដ្ឋានណាមួយដែលបង្ហាញថាជនជាប់ចោទមិនបានផ្ដល់ចម្លើយដល់ឧត្ដមស្នងការទទួលបន្ទុកសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិដោយស្ម័គ្រចិត្តនោះទេ។ នៅពេលដែលឯកសារត្រូវបានដាក់ចូលក្នុង

---

[7] ឯកសារលេខ 19,25 (ឧបសម្ព័ន្ធ"គ" នៃដីកាសន្និដ្ឋានបញ្ជូនរឿងទៅស៊ើបសួរ) ("របាយការណ៍របស់ ឈឹន ស្ទឺ")។

[8] T., ថ្ងៃទី៦ ខែមេសា ឆ្នាំ២០០៩ ទំព័រ 9។ T., ថ្ងៃទី៧ ខែមេសា ឆ្នាំ២០០៩ ទំព័រ 36-57 និង T., ថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៩ ទំព័រ64។

សំណុំរឿងហើយនោះ ឯកសារទាំងនោះអាចនឹងត្រូវបានអង្គជំនុំជម្រះយកមកពិចារណា ហើយបញ្ហាចោទតែមួយគត់ គឺការថ្លឹងថ្លែងទៅលើឯកសារទាំងនោះ។ ប្រសិនបើខ្លួនចង់ជំទាស់ទៅនឹងឯកសារទាំងនេះ មេធាវីការពារក្តីគួរតែបានប្រើប្រាស់នីតិវិធីមោឃៈភាពនៅក្នុងដំណាក់កាលស៊ើបសួរនៃដំណើរការនីតិវិធីដែលមានចែងនៅក្នុងវិធាន ៧៦(២) នៃវិធានផ្ទៃក្នុង។ ដោយការខកខានមិនបានធ្វើដូច្នេះ ដីកាដំណោះស្រាយបានកែតម្រូវនូវកំហុសឆ្គងដែលមាននៅក្នុងឯកសារទាំងនោះ ហើយយោងតាមវិធាន ៧៦(៧) នៃវិធានផ្ទៃក្នុង មេធាវីការពារក្តីត្រូវបានហាមមិនឲ្យស្នើសុំដកភស្តុតាងនេះចេញពីសំណុំរឿង[9]។

៤. យោងតាមមេធាវីការពារក្តី វាមិនមែនជាកាតព្វកិច្ចក្នុងការស្នើសុំមោឃៈភាពឯកសារទាំងនេះ នៅក្នុងដំណាក់កាលស៊ើបសួរនោះទេ។ វិធាន ៧៦ នៃវិធានផ្ទៃក្នុងមិនអនុវត្តចំពោះឯកសារទាំងឡាយដែលកំពុងចោទជាបញ្ហានោះទេ។ វិធានដែលកំពុងអនុវត្តជំនួស គឺវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង ដែលយោងតាមវិធាននេះ ឯកសារទាំងឡាយដែលកំពុងចោទជាបញ្ហាគួរតែត្រូវបានបដិសេធដោយអង្គជំនុំជម្រះសាលាដំបូង ដោសារតែឯកសារទាំងនោះមិនសមស្របក្នុងការបង្ហាញភស្តុតាងអំពីអង្គហេតុ ដែលឯកសារទាំងនោះយកមកបង្ហាញភស្តុតាង[10]។

## គ. ការពិភាក្សា

### ក. ក្របខ័ណ្ឌច្បាប់

#### i. *បទបញ្ញត្តិនៃវិធានផ្ទៃក្នុងពាក់ព័ន្ធនឹងភាពអាចទទួលយកធ្វើជាភស្តុតាង (វិធាន ៨៧)*

៥. វិធាន ៨៧(១) នៃវិធានផ្ទៃក្នុងបានចែងថា "លើកលែងតែមានបញ្ញត្តិផ្សេងក្នុងវិធានផ្ទៃក្នុងនេះរាល់ភស្តុតាងទាំងអស់ត្រូវតែទទួលយក"។ វិសាលភាពនៃគោលការណ៍ទូទៅនេះត្រូវបាន

[9] T., ថ្ងៃទី៧ ខែមេសា ឆ្នាំ២០០៩ ទំព័រ៥៤-៥៦។ T., ថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៩ ទំព័រ18-21។

[10] T., ថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៩ ទំព័រ 33-41។

បញ្ជាក់ដោយវិធាន ៨៧(២) នៃវិធានផ្ទៃក្នុង ដែលបានចែងថា "សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ត្រូវផ្អែកលើភស្តុតាងដែលបានដាក់ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ហើយដែលភស្តុតាងនោះត្រូវឆ្លងកាត់ការដេញដោល"។ វិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង បានបង្ហាញថា ភស្តុតាងដែលមាននៅក្នុងសំណុំរឿងត្រូវបានចាត់ទុកថា បានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង បើសិនជាខ្លឹមសាររបស់វាត្រូវបានសង្ខេប ឬត្រូវបានអាននៅក្នុងសវនាការ។

៦. ទោះបីជាពាក្យពេចន៍នៃវិធាន ៨៧(៣) សំដៅទៅលើ "ភស្តុតាងដែលយកមកពីក្នុងសំណុំរឿងក៏ដោយ" ក៏តាមខ្លឹមសារនៃវិធាន ៨៧ ទាំងមូល គឺថាសម្ភារៈទាំងអស់ដែលមាននៅក្នុងសំណុំរឿង គឺមិនមែនជា "ភស្តុតាង"ទេ លុះត្រាតែសម្ភារៈទាំងនោះត្រូវបានដាក់បង្ហាញនៅពេលសវនាការអនុលោមតាមវិធាន ៨៧(២)។ ខណៈដែលសម្ភារៈដែលមាននៅក្នុងសំណុំរឿង អាចត្រូវបានលើកយកមកដេញដោលនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង តាមសំណើរបស់ភាគីឬតាមគំនិតផ្ដួចផ្ដើមរបស់ខ្លួន អង្គជំនុំជម្រះអាចបដិសេធមិនយកមកធ្វើជាភស្តុតាងបានដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដូចដែលបានគូសបញ្ជាក់នៅក្នុងវិធាន ៨៧(៣) ពោលគឺមិនជាប់ពាក់ព័ន្ធ មិនអាចបញ្ជាក់ពីអង្គហេតុដែលត្រូវបានចោទប្រកាន់ មិនអាចរកបានភស្តុតាងក្នុងរយៈពេលសមស្របណាមួយ ឬដោយសារតែល្មើសទៅនឹងបទដ្ឋានច្បាប់ជាមូលដ្ឋានពាក់ព័ន្ធនឹងវិធាននៃភស្តុតាង។

៧. ដូច្នេះដើម្បីអាចយកមកប្រើប្រាស់ជាភស្តុតាងបាន សម្ភារៈដែលមាននៅក្នុងសំណុំរឿងត្រូវបំពេញឱ្យបាននូវបទដ្ឋានអប្បបរមានៃភាពជាប់ពាក់ព័ន្ធនិងភាពគួរឱ្យជឿជាក់បាន ដែលចាំបាច់ដើម្បីឱ្យសម្ភារៈទាំងនោះអាចដាក់ដេញដោលបាននៅចំពោះមុខអង្គជំនុំជម្រះ។ នៅពេលដែលសម្ភារៈត្រូវបានដាក់បង្ហាញនៅចំពោះមុខអង្គជំនុំជម្រះ តម្លៃដាក់បន្ទុកនៃភស្តុតាងនេះ និងការថ្លឹងថ្លែងដើម្បីឱ្យមានការយល់ស្របទៅនឹងភស្តុតាងនោះ នឹងត្រូវបានធ្វើការវាយតម្លៃដោយអង្គជំនុំជម្រះ[11]។

[11] វិធាន៨៧(៣) នៃវិធានផ្ទៃក្នុងអនុញ្ញាតឱ្យអង្គជំនុំជម្រះអាចបដិសេធចំពោះពាក្យសុំឱ្យពិនិត្យភស្តុតាង បើយល់ឃើញថា៖ ក) មិនជាប់ពាក់ព័ន្ធ ឬជាការស្នើសុំជាន់គ្នា ខ) មិនអាចរកបានក្នុងរយៈពេលសមស្របណាមួយ គ) មិន

## ii. *វិសាលភាពនៃនីតិវិធីមោឃៈភាពទាក់ទិននឹង "ផ្នែកណាមួយនៃដំណើរការនីតិវិធី" (pièce de la procédure) (វិធាន ៧៦ នៃវិធានផ្ទៃក្នុង)*

៨. វិធាន ៧៦ នៃវិធានផ្ទៃក្នុង អនុញ្ញាតឲ្យគ្រប់ភាគីទាំងអស់នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត ផ្ញើសំណើសុំមោឃៈភាព និងសុំដកចេញពីសំណុំរឿង "នូវផ្នែកណាមួយនៃដំណើការនីតិវិធី"[12] ដែលត្រូវបានគេចោទប្រកាន់ថាមានកំហុសសំខាន់ ផ្នែកទម្រង់ ឬក៏មានវិការៈផ្នែកនីតិវិធី។ យោងតាមវិធាន ៧៦(៧) នៃវិធានផ្ទៃក្នុង ដីកាដំណោះស្រាយ នៅពេលចូលស្ពាពរ ត្រូវ "កែតម្រូវកំហុសនៃការមិនគោរពវិធានបញ្ញត្តិនៅក្នុងការស៊ើបសួរ។ គ្មានបញ្ហាណាមួយដែលពាក់ព័ន្ធនឹងកំហុសនីតិវិធីបែបនេះអាចត្រូវបានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឬអង្គជំនុំជម្រះតុលាការកំពូលបានឡើយ"។

៩. អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ឃើញថា ឃ្លាថា "ផ្នែកណាមួយនៃដំណើរការនីតិវិធី" នៅក្នុងវិធាន ៧៦(១) នៃវិធានផ្ទៃក្នុងជាភាសាអង់គ្លេសមានន័យមិនច្បាស់លាស់ទេ ផ្ទុយទៅវិញ សំណៅជាភាសាបារាំង - *pièce de la procédure* - មានន័យច្បាប់យ៉ាងច្បាស់លាស់។ មាត្រា ១៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង សំដៅដល់ទស្សនៈ "*actes ou pièce de la procédure*"[13] ដែលទាក់ទងយ៉ាងច្បាស់លាស់ទៅនឹងកិច្ចស៊ើបសួរនិងលទ្ធផលជាក់ស្តែងនៃកិច្ចស៊ើបសួរទាំងនោះប៉ុណ្ណោះ។ ឧបមាថា សំណើសុំមោឃៈភាព

---

សមស្របសម្រាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភស្តុតាង ឃ) ច្បាប់មិនអនុញ្ញាត ឬ ង) មានចេតនាពន្យាកិច្ចដំណើរការនីតិវិធី ឬគ្មានប្រយោជន៍។

[12] ជាភាសាបារាំង, *ផ្នែកនៃដំណើរការនីតិវិធី (សូមមើលខាងក្រោម)* ។

[13] មាត្រា១៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌរបស់ប្រទេសបារាំងបានចែងថាដូចតទៅ៖ "គ្រប់ដំណាក់កាលទាំងអស់ អង្គជំនុំជម្រះសាលាដំបូងអាចធ្វើការមោឃភាពកិច្ចស៊ើបសួរ ឬផ្នែកណាមួយនៃដំណើរការនីតិវិធីរបស់ចៅក្រមស៊ើបអង្កេត អយ្យការ ឬភាគីនានា" (មានគូសបញ្ជាក់បន្ថែម)។



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C

អាចសំដៅលើលិខិតចាត់ឱ្យស៊ើបសួរជំនួស ដែលផ្តល់អំណាចឱ្យមានការបញ្ឈប់ការសន្ទនាតាមទូរស័ព្ទ ក៏ដូចជាប្រតិចារឹកនៃការទំនាក់ទំនងដែលត្រូវបានរារាំង ឬកំណត់ហេតុពីកាយសម្បទាខ្លួនឯងផ្ទាល់។ ផ្នែកណាមួយនៃនីតិវិធី *(pièce de la procédure)* គឺជាលទ្ធផល ដែលបានមកពីកិច្ចដែលធ្វើឡើងដោយចៅក្រមស៊ើបសួរ ឬ បុគ្គលដែលត្រូវបានបំពេញកិច្ចជាអ្នកតំណាងឱ្យតុលាការប៉ុណ្ណោះ។ សម្ភារៈប្រភេទនេះ គឺជាកម្មវត្ថុសុំមោឃៈភាពកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៧៦ នៃវិធានផ្ទៃក្នុង។ បើមិនដូច្នេះទេ កំហុសណាមួយដែលមាននៅក្នុងកិច្ចនៃនីតិវិធី ត្រូវបានកែតម្រូវដោយដីកាដំណោះស្រាយ ស្របតាមវិធាន ៧៦(៧) នៃវិធានផ្ទៃក្នុង។

១០. ផ្ទុយទៅវិញ ច្បាប់យុត្តិសាស្ត្ររបស់តុលាការកំពូលបារាំង (*Cour de Cassation*) បានយល់ឃើញថា លិខិតនានា ឯកសារនានា ឬកំណត់ហេតុនានា ដែលបានដាក់ជូនដោយភាគីឬសាក្សី ដែលជាផ្នែកមួយនៃសំណុំរឿង មិនមែនជា ផ្នែកមួយនៃនីតិវិធី (*pièce de la procédure*) ទេ[14]។ ចៅក្រមស៊ើបសួរមានកាតព្វកិច្ចបញ្ចូលសម្ភារៈបែបនេះនៅក្នុងអំឡុងពេលដំណើរការនីតិវិធី ហើយមិនអាចបដិសេធមិនដាក់ចូលក្នុងសំណុំរឿងនូវសម្ភារៈដែលបានដាក់ជូនដោយភាគីនេះបានទេ ទោះបីជាសម្ភារៈនោះត្រូវបានចោទប្រកាន់ថាទទួលបានតាមរយៈបែបបទដែលមិនត្រឹមត្រូវក៏ដោយ។ ភស្តុតាងនេះមិនត្រូវបានគ្របដណ្តប់ដោយវិធាន ៧៦ ទេ។ កំហុសណាមួយដែលមាននៅក្នុងសម្ភារៈនោះ អាចត្រូវបានលើកយកមកធ្វើការពិភាក្សានៅក្នុងអំឡុងពេលដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងជាជំនួសវិញ នៅពេលមានសំណើសុំឱ្យយកសម្ភារៈដែលមានបញ្ហានេះមកប្រើប្រាស់នៅចំពោះមុខអង្គជំនុំជម្រះ។

---

[14] *សូមមើលឧទាហរណ៍ តុលាការកំពូលបារាំង (Cour de Cassation),* អង្គជំនុំជម្រះលើផ្នែកឧក្រិដ្ឋកម្ម (ថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៩៩) ព្រឹត្តិប័ត្រព្រហ្មទណ្ឌលេខ ៥៩។ *តុលាការកំពូលបារាំង (Cour de Cassation),* អង្គជំនុំជម្រះលើផ្នែកឧក្រិដ្ឋកម្ម ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៣, បោះពុម្ពផ្សាយ ដោយទស្សនាវដ្តីច្បាប់ Dalloz ឆ្នាំ ២០០៤ ទំព័រ៦៧០។



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E.C.C.C.E.T.C.

00332877



១១. ដោយសារតែច្បាប់កម្ពុជាប្រើប្រាស់ឃ្លាដែលមានន័យស្មើគ្នានឹង pièce de la procédure ដែលមាននៅក្នុងច្បាប់បារាំងនោះ អង្គជំនុំជម្រះសាលាដំបូងពិចារណាឃើញថា ទស្សនៈនៅក្នុងវិធានផ្ទៃក្នុងនេះ ក៏បានសំដៅលើកិច្ចស៊ើបសួរដែលធ្វើដោយសហចៅក្រមស៊ើបសួរ ឬបុគ្គលដែលបំពេញកិច្ចជាអ្នកតំណាងឲ្យតុលាការ និង សំដៅលើសម្ភារៈទាំងឡាយ ដែលកើតចេញមកពីកិច្ចទាំងនេះតែមួយប៉ុណ្ណោះ[15]។ ដូច្នេះ មានតែកិច្ចទាំងនេះនិងសម្ភារៈដែលជាលទ្ធផលកើតចេញមកពីកិច្ចទាំងនេះតែប៉ុណ្ណោះដែលស្ថិតនៅក្នុងវិសាលភាពនៃនីតិវិធីមោឃៈភាព នៅចំពោះមុខអង្គបុរេជំនុំជម្រះ។ វិធាននេះមិនគ្របដណ្តប់លើសម្ភារៈ និង ឯកសារនានាដែលដាក់ជូនដោយភាគីទេ រីឯកំហុសឆ្គងដែលមាននៅក្នុងសម្ភារៈទាំងនេះមិនអាចកែតម្រូវបានដោយដីកាដំណោះស្រាយបានទេ អនុលោមតាមវិធាន ៧៦(៧)។ កំហុសទាំងឡាយដែលមាននៅក្នុង សម្ភារៈ និង ឯកសារទាំងនេះនឹងត្រូវធ្វើការពិចារណា នៅក្នុងពេលពិនិត្យមើលនៅចំពោះមុខអង្គជំនុំជម្រះ ដើម្បីធ្វើការសម្រេចអំពីការទទួលយក សម្ភារៈ និង ឯកសារទាំងនោះមកប្រើប្រាស់ធ្វើជាភស្តុតាង នៅពេលធ្វើសវនាការ។

១២. ពុំមានសម្ភារៈដែលចោទជាបញ្ហានៅក្នុងសេចក្តីសម្រេចនេះណាមួយ មាន *pièce de la procédure* យោងតាមនិយមន័យខាងលើនោះទេ ហេតុនេះហើយ សម្ភារៈទាំងអស់មិនត្រូវបានគ្របដណ្តប់ដោយវិធាន ៧៦ នៃវិធានផ្ទៃក្នុងនេះទេ។ ទោះបីជាយ៉ាងណាក៏ដោយ សម្ភារៈ ទាំងអស់នោះគឺស្ថិតនៅក្នុងសំណុំរឿងដែលគូភាគីអាចស្នើសុំយកមកដាក់នៅចំពោះមុខអង្គជំនុំជម្រះបាន។ តាមការអធិប្បាយខាងលើ ការប្រើប្រាស់សម្ភារៈបែបនេះនៅក្នុងតុលាការអាចត្រូវបានជំទាស់ ឬមួយដោយភាគី ឬមួយដោយអង្គជំនុំជម្រះតាមគំនិតរបស់ខ្លួន ហើយអង្គជំនុំជម្រះអាចបដិសេធក្នុងការយកសម្ភារៈទាំងនោះមកធ្វើជាភស្តុតាង យោងតាមលក្ខណៈវិនិច្ឆ័យ ដូចជាភាពមិនពាក់ព័ន្ធ ឬភាពមិនគួរឲ្យជឿជាក់បានជាដើម។

---

[15] *ក្នុងចំណោមមាត្រានានា* សូមមើលមាត្រា២៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។



CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C E T C

## ខ. ការវិភាគលើសម្ភារៈជាក់លាក់

### *i. ចម្លើយរបស់សាក្សីដែលបានទទួលមរណភាព និងអត្ថបទពាក់ព័ន្ធរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា*

១៣. ចម្លើយរបស់សាក្សីដែលបានទទួលមរណភាពត្រូវបានកត់ត្រាដោយអ្នកតំណាងមជ្ឈមណ្ឌលឯកសារកម្ពុជា កាលពីថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០១ និងអត្ថបទរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាត្រូវបានកត់ត្រានៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៣។ ទោះបីជាមានការព្យាយាមសួរយកចម្លើយសាក្សីទាំងនេះក៏ដោយក៏សាក្សី ហាម អ៊ិន និង អ៊ឹម វ៉ន បានទទួលមរណភាព នៅមុនពេលសួរយកចម្លើយអស់ទៅហើយ[16]។

១៤. ច្បាប់យុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុបបង្ហាញថា សិទ្ធិក្នុងការពិនិត្យលើសាក្សីដែលជាផ្នែកនៃសិទ្ធិក្នុងការទទួលបាននូវការកាត់ទោសដោយយុត្តិធម៌ ជាធម្មតាបានសន្មតជាមុនថា ភស្តុតាងនឹងត្រូវនាំយកមកបង្ហាញនៅក្នុងសវនាការសាធារណៈ ដោយមានវត្តមានរបស់ជនជាប់ចោទ ដែលអាចមើលឃើញការជជែកតទល់គ្នា។ នៅពេលមានការលើកលែងចំពោះគោលការណ៍ទូទៅនេះ តាមវិធានទូទៅ ជនជាប់ចោទត្រូវបានផ្តល់នូវឱកាសគ្រប់គ្រាន់ និងសមស្របដើម្បីធ្វើការជំទាស់និងអាចសួរសំណួរទៅសាក្សីដែលប្រឆាំងនឹងគាត់ផងដែរ ទាំងនៅពេលដែលគាត់ផ្តល់ចម្លើយ ឬនៅដំណាក់កាលបន្ទាប់ទៀត[17]។

---

[16] T., ថ្ងៃទី៧ ខែមេសា ឆ្នាំ២០០៩ ទំព័រ 36 និង 51។ *សូមមើលផងដែរ* "សំណើរបស់សហព្រះរាជអាជ្ញាស្នើសុំធ្វើបទសម្ភាសន៍សាក្សីចំនួន៣៣ និងការទទួលយកឯកសារពាក់ព័ន្ធទៅនឹងសាក្សីនៅក្នុងសំណុំរឿង។ ឧបសម្ព័ន្ធ៤៖ បទសម្ភាសន៍ជាមួយ ហាម អ៊ិន ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០១" ឯកសារលេខ D59 ឧបសម្ព័ន្ធ៤ ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០១។ សំណើរបស់សហព្រះរាជអាជ្ញាស្នើសុំធ្វើបទសម្ភាសន៍សាក្សីចំនួន៣៣ និងការទទួលយកឯកសារពាក់ព័ន្ធទៅនឹងសាក្សីនៅក្នុងសំណុំរឿង។ ឧបសម្ព័ន្ធ១២៖ មជ្ឈមណ្ឌលឯកសារកម្ពុជា - ទាក់ទងនឹងបញ្ជាមន្ត្រីសន្តិសុខម-១៣, សម្ភាសន៍ជាមួយ Im Vorn" ឯកសារលេខ D59 ឧបសម្ព័ន្ធ១២ ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៣។

[17] *សូមមើលឧទាហរណ៍ រឿងក្តី Bonev តទល់នឹងប្រទេសប៊ុលហ្គារី,* ECHR 60018/00 (2006), កថាខណ្ឌ៤៣។ *រឿងក្តី Gossa តទល់នឹង ប្រទេសប៉ូឡូញ,* ECHR 47968/99 (2007) កថាខណ្ឌ៥៣។ *រឿងក្តី Luci តទល់នឹងប្រទេស*



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C E T C

១៥. តុលាការឧក្រិដ្ឋកម្មអន្តរជាតិផ្សេងៗទៀតអនុញ្ញាតឱ្យមានការប្រើប្រាស់ភស្តុតាង នៅក្នុងទម្រង់ជាកំណត់ហេតុលាយលក្ខណ៍អក្សររបស់សាក្សីដែលបានទទួលមរណភាព ឬសាក្សីដែលគេមិនអាច រកឃើញដោយការព្យាយាមសមរម្យ នៅពេលដែលភស្តុតាងនៅបានបំពេញលក្ខខណ្ឌមួយចំនួន[18]។ កត្តាដែលត្រូវពិចារណា ថាតើត្រូវទទួលយកភស្តុតាងបែបនេះ ឬមិនទទួលយកនោះ រួមមាន កាលៈទេសៈដែលចម្លើយនោះត្រូវបានធ្វើនិងត្រូវបានកត់ត្រា ថាតើចម្លើយបើកផ្លូវឱ្យមានការសួរដេញដោលដោយភាគីប្រឆាំងដែលគេកំពុងប្រើភស្តុតាងនេះដើម្បីចោទប្រកាន់ឬទេ និងថាតើចម្លើយនោះទាក់ទងទៅនឹងព្រឹត្តិការណ៍ដែលនាំឱ្យមានភស្តុតាងផ្សេងទៀតដែរឬទេ[19]។ នៅពេលដែលភស្តុតាងឈានទៅរកការបង្ហាញពីអំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទ ដូចដែលត្រូវបានចោទប្រកាន់នោះ នេះគឺជាកត្តាដែលប្រឆាំងនឹងភាពអាចទទួលយកភស្តុតាងបែបនេះ ឬក៏ជាផ្នែកនៃភស្តុតាងនោះ[20]។

---

*ស្វីស* ECHR 12433/86 (1992) កថាខណ្ឌ47។ *រឿងក្តី Doorson តទល់នឹង ប្រទេសហូឡង់* ECHR 20524/92 (1996) កថាខណ្ឌ76។

[18] *សូមមើល* វិធាន *៩២ ស្ទួន* និង *quarter* នៃវិធាននីតិវិធី និងភស្តុតាងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសយូហ្គោស្លាវី (ICTY), និង តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន (SCSL) ។

[19] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Popovic,* អង្គជំនុំជម្រះសាលាដំបូងរបស់តុលាការ ICTY សំណុំរឿងលេខ IT-05-88-T "សេចក្តីសម្រេចលើពាក្យសុំរបស់រដ្ឋអាជ្ញាស្នើសុំឱ្យទទួលយកភស្តុតាងដោយអនុលោមតាមវិធាន ៩២ *quater*" ថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៨ កថាខណ្ឌ៣១ (ដោយពិចារណាផងដែរ ថាតើចម្លើយទាំងនោះធ្វើឡើងដោយមានការស្បថ ដោយចុះហត្ថលេខាដោយសាក្សីដោយភ្ជាប់មកជាមួយនូវការទទួលស្គាល់ដែលថាចម្លើយទាំងនេះពិតជាត្រឹមត្រូវ និងបានធ្វើឡើងដោយមានជំនួយពីអ្នកបកប្រែផ្ទាល់មាត់ដែលមានសមត្ថភាព)។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Milutinovic* អង្គជំនុំជម្រះសាលាដំបូងរបស់តុលាការICTY សំណុំរឿងលេខ IT-05-87-T, "សេចក្តីសម្រេចលើពាក្យសុំរបស់រដ្ឋអាជ្ញាស្នើសុំឱ្យទទួលយកភស្តុតាងដោយអនុលោមតាមវិធាន ៩២ *quater*" ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ ២០០៧ កថាខណ្ឌ៧។

[20] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Taylor* សំណុំរឿងលេខSCSL-03-01 "សេចក្តីសម្រេចជាសាធារណចំពោះឧបសម្ព័ន្ធសម្ងាត់ C ដល់ Eរបស់បណ្តឹងរបស់រដ្ឋអាជ្ញាស្នើសុំឱ្យទទួលយកប្រតិចារឹករបស់តុលាការពីមុនរបស់សាក្សី TF1-021 និងសាក្សី TF1-083 អនុលោមតាមវិធាន៩២ *quater*" ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០០៩ កថាខណ្ឌ១៨។

00332880



១៦. អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ឃើញថា ជនជាប់ចោទបានតវ៉ាអំពីភាពត្រឹមត្រូវនៃចម្លើយទាំងនេះ និងកត់សម្គាល់ឃើញថា ជនជាប់ចោទមិនមានឱកាសតទល់ជាមួយសាក្សីទាំងនេះដែលមិនត្រូវបានស្តាប់ចម្លើយនៅចំពោះមុខ ក.ស.ច.ស ហើយ បានទទួលមរណភាពអស់ទៅហើយ។ ទោះបីជាព្រឹត្តិការណ៍នៅមន្ទីរ ម-១៣ ជាទូទៅ គ្រាន់តែជាប្រវត្តិក៏ដោយ ភាពពាក់ព័ន្ធនៃបរិបទនៅក្នុងសវនាការនេះ គឺជាចម្លើយទាំងពីរ ដែលបានសំដៅលើអំពើ និងការប្រព្រឹត្តិឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់លើជនជាប់ចោទ[21]។ វា ប្រាកដណាស់ថា ពុំមានការស្បថណាមួយដែលត្រូវបានធ្វើដោយសាក្សី ឬអ្នកបកប្រែភាសានោះទេ និងថាការសួរយកចម្លើយមិនត្រូវបានថតយកសម្លេងនោះទេ ហើយថាកំណត់ហេតុដែលជាលទ្ធផលនោះមិនត្រូវបានចុះហត្ថលេខានោះទេ។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថែមទៀត អំពីភាពមិនស្របគ្នាខ្លះត្រូវបានលើកឡើងដោយសហព្រះរាជអាជ្ញា ពាក់ព័ន្ធនឹងសំណៅជាភាសាអង់គ្លេសនិងសំណៅជាភាសាបារាំង នៃឯកសារ D59/4[22]។ អង្គជំនុំជម្រះសម្រេចមិនទទួលយកចម្លើយទាំងនេះដោយសារតែភាពដើម ខ្លឹមសារ ចរិតលក្ខណៈមិនឯកភាពគ្នា ព្រមទាំងអលទ្ធភាពរបស់ជនជាប់ចោទ ក្នុងការជជែកតវ៉ាពីការប្រឆាំងជំទាស់របស់ខ្លួន។ កត្តាទាំងនេះបានធ្វើឲ្យចម្លើយទាំងនេះមិនមានលក្ខណៈសមស្រប ដើម្បីបង្ហាញភស្តុតាងអំពីអង្គហេតុ ដូច

[21] ការស្តាប់ចម្លើយ ហាម អ៊ីន ដែលជាអ្នកទោស និងជាបុគ្គលិកនៅមន្ទីរ ម-១៣ យោងលើការធ្វើទារុណកម្មដែលត្រូវបានប្រព្រឹត្តឡើងដោយជនជាបើចោទនៅ ម-១៣ និងផ្តល់ឲ្យនូវចំនួនប៉ាន់ស្មានច្រើនលើសចំនួន នៃការសម្លាប់ដែលបានធ្វើឡើងនៅទីនោះ ដែលបានបញ្ជាក់ដោយជនជាប់ចោទក្នុងពេលសវនាការ។ ការស្តាប់ចម្លើយ អ៊ីន វន យោងយ៉ាងទូលំទូលាយទៅលើការជាប់ពាក់ព័ន្ធដែលត្រូវបានចោទប្រកាន់របស់ជនជាប់ចោទក្នុង ការសួរចម្លើយ ការធ្វើទារុណ កម្ម និងការសម្លាប់ នៅមន្ទីម-១៣ (ប្រតិចារឹកចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០០៩, ទំព័រទី36-37 និងទី51-52; "សំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យស្តា ប់ចម្លើយសាក្សីចំនួន៣៣ នាក់ និង សុំឲ្យដាក់បញ្ចូលឯកសារដែលពាក់ព័ន្ធនឹងសាក្សីទាំងនោះទៅក្នុងសំណុំរឿង; ឧបសម្ព័ន្ធ ៤: បទសម្ភាសន៍ជាមួយ ហាម អ៊ីន ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០១",ឯកសារលេខD59 ឧបសម្ព័ន, ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០១ និង "សំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យស្តាប់ចម្លើយសាក្សីចំនួន៣៣ នាក់ និងសុំឲ្យដាក់បញ្ចូលឯកសារដែលពាក់ព័ន្ធនឹងសាក្សីទាំងនោះទៅក្នុងសំណុំរឿង; ឧបសម្ព័ន១២: DC-Cam - ទាក់ទងនឹងមន្ទីរសន្តិសុខម-១៣, បទសម្ភាសន៍របស់ អ៊ីន វន ", ឯកសារលេខ D59 ឧបសម្ព័ន្ធ១២, ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៣)។

[22] ប្រតិចារឹក ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០០៩ ទំព័រទី43-45, 54 ។

គោលបំណងនៃចម្លើយទាំងនោះទេ ដូចមានចែងនៅក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។

១៧. នៅក្នុងការប្រព្រឹត្តិទៅនៃដំណើរការនីតិវិធី អង្គជំនុំជម្រះបានសម្អាងលើអត្ថបទមួយដែលមានចំណងជើងថា " ប្រព័ន្ធសន្តិសុខនៃមន្ទីរម-១៣ របស់ភូមិភាគពិសេស" ដែលបោះពុម្ពផ្សាយដោយទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា *ស្វែងរកការពិត* លេខពិសេសជាភាសាអង់គ្លេស កាលពីខែកក្កដា ឆ្នាំ២០០៣ ហើយត្រូវបានបញ្ចូលនៅក្នុងដីកាសម្រេចបញ្ជូនរឿងឲ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា លេខ ១.៨[23]។ អត្ថបទ ដែលរៀបរាប់យ៉ាងពិស្តារអំពីការបង្កើត រចនាសម្ព័ន្ធ និងដំណើរការនៃមន្ទីរ ម-១៣ សម្អាង ជាទូទៅលើតែចម្លើយនានារបស់សាក្សីដែលបានទទួលមរណភាពនោះ។ មេធាវីការពារក្ដីបានជំទាស់ទៅនឹងការប្រើប្រាស់ការបោះពុម្ពផ្សាយនេះនៅពេលជំនុំជម្រះ[24]។ ដោយសារតែចម្លើយរបស់សាក្សីដែលបានទទួលមរណភាព ដែលចម្លើយនោះត្រូវបានគេយកមកប្រើប្រាស់ជាឯកសារយោងសម្រាប់ការបោះពុម្ពផ្សាយ ត្រូវបានបដិសេធចោលហើយនោះ អត្ថបទរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានេះក៏ត្រូវបានបដិសេធមិនយកធ្វើជាភស្តុតាងនៅក្នុងរឿងក្ដីនេះដែរ។

*ii. ការសួរយកចម្លើយរបស់ឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិលើ*ជនជាប់ចោទ

១៨. យោងតាមសម្ដីរបស់ជនជាប់ចោទ ការសួរយកចម្លើយនេះត្រូវបានធ្វើឡើង នៅក្នុងឆ្នាំ១៩៩៩ ដោយលោក Christophe Peschoux ដែលជាតំណាងរបស់ឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ដោយមានវត្តមានរបស់អ្នកដទៃទៀតផងដែរ[25]។ ជនត្រូវចោទបានលើកឡើងថា គាត់ត្រូវគេសួរចម្លើយភ្លាមបន្ទាប់ពីគាត់ត្រូវគេប្រាប់ថាលោក

---

[23] ឯកសារ 1.8 នៃសេចក្ដីសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ("អត្ថបទ DC-Cam")។

[24] ប្រតិចារឹកចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៩ ទំព័រទី35 ។

[25] កំណត់ហេតុនៃការសួចម្លើយជនជាប់ចោទ, ឯកសារលេខ D38, ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០០៨ ទំព័រទី2-3 ។

Peschoux មាន "លិខិតប្រគល់សិទ្ធិរបស់អង្គការសហប្រជាជាតិ"[26]។ គាត់តវ៉ាថា ការបង្ហាញលិខិតនេះហាក់ដូចជាបង្ហាញសិទ្ធិក្នុងការសួរសំណួរគាត់ ដែលហាក់បីដូចជាធ្វើឲ្យគាត់មានកាតព្វកិច្ចត្រូវតែផ្តល់ចម្លើយ[27]។ ទោះបីជាមានការយល់ព្រមថា គាត់បានឆ្លើយទៅនឹងសំណួរនានា ដែលត្រូវបានចោទសួរនោះដោយសេរីក៏ដោយ ជនជាប់ចោទតវ៉ាថា គាត់មិនបានទទួលព័ត៌មានអំពីសិទ្ធិនៅស្ងៀមមិនឆ្លើយតប ក៏ដូចជាមិនត្រូវបានគេរំលឹកថា ការសួរយកចម្លើយអាចត្រូវបានប្រើប្រាស់នៅក្នុង ដំណើរការនីតិវិធីរបស់តុលាការនាពេលក្រោយពីនោះទេ[28]។ បន្ថែមពីលើរបៀបនៃការសួរសំណួរ ជនជាប់ចោទបានតវ៉ាថា គាត់ត្រូវបានអូសទាញឲ្យចូលរួមក្នុងការសួរយកចម្លើយ ទៅតាមការក្លែងបន្លំភូតកុហក ហើយនៅក្នុងពេលសួរយកចម្លើយនោះ គាត់ត្រូវគេណែនាំឲ្យធ្វើដំណើរទៅប្រទេសថៃ ក្នុងគោលបំណងដើម្បីឲ្យគេបញ្ជូនគាត់ទៅកាត់ទោសនៅប្រទេសប៊ែលហ្ស៊ិក[29]។ ការិយាល័យសហព្រះរាជអាជ្ញាបានតវ៉ាចំពោះការពិចារណានេះ ដោយគូសបញ្ជាក់ការសួរយកចម្លើយនេះគឺធ្វើឡើងដោយស្ម័គ្រចិត្ត ព្រមទាំងពីអង្គហេតុដែលថាការសួរយកចម្លើយនោះមិនត្រូវបានធ្វើឡើងដោយមន្ត្រីតុលាការ ក៏ដូចជាមិនធ្វើឡើងនៅក្នុងបរិបទនៃការចាប់ខ្លួន ឬការផ្តន្ទាទោសដែលអាចកើតមាននោះឡើយ[30]។ បញ្ហាចោទជាច្រើនពាក់ព័ន្ធនឹងយថាភាពនៃការធ្វើកំណត់ហេតុលើការសួរយកចម្លើយក៏ត្រូវបានលើកឡើង

---

[26] ប្រតិចារឹកចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៩ ទំព័រទី44; កំណត់ហេតុនៃការសួរចម្លើយជនជាប់ចោទ, ឯកសារលេខ D38, ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០០៨, ទំព័រទី2-3។

[27] ប្រតិចារឹកចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៩ ទំព័រទី54។

[28] កំណត់ហេតុនៃការសួចម្លើយជនជាប់ចោទ, ឯកសារលេខ D72, ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០០៩។

[29] ប្រតិចារឹកចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៩ ទំព័រទី50-60។

[30] ប្រតិចារឹកចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០០៩ ទំព័រទី10-11 (ពិពណ៌នាការសម្ភាសន៍នោះថា "ត្រូវបានផ្តល់ឲ្យដោយស្ម័គ្រចិត្តដល់មន្ត្រីដែលមានអាណត្តិត្រូវប្រមូលភស្តុតាងនៃការរំលោភសិទ្ធិមនុស្ស"); "សេចក្តីសង្កេតសហព្រះរាជអាជ្ញាអំពីការដាក់ជនជាប់ចោទឲ្យប្រឈមមុខនឹងកំណត់ហេតុនៃបទសម្ភាសន៍របស់គាត់ជាមួយ UNHCHR", ឯកសារលេខ E43/3, ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០០៩, ទំព័រទី1។ ភាគីទាំងឡាយក៏ជំទាស់នឹងកាលានុវត្តនៃការជំទាស់របស់ក្រុមការពារក្តីទៅនឹងការធ្វើបតសម្ភាសន៍នោះ៖ ប្រតិចារឹកចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០០៩, ទំព័រទី10-11; "សេចក្តីសង្កេតសហព្រះរាជអាជ្ញា អំពីការដាក់ជនជាប់ចោទឲ្យប្រឈមមុខនឹងកំណត់ហេតុនៃបទសម្ភាសន៍របស់គាត់ជាមួយ UNHCHR", ឯកសារលេខ E43/3, ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០០៩ ទំព័រទី2; "ការសង្កេតរបស់សហមេធាវី



TRIAL CHAMBER CHAMBRE DE PREMIERE INSTANCE E C C C

ដោយភាគីផងដែរ[31]។

១៩. សិទ្ធិនៅស្ងៀមមិនឆ្លើយតប និងបុព្វសិទ្ធិអំពីការមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង ដែលមានចែងនៅក្នុងវិធាន ២១(ឃ) នៃវិធានផ្ទៃក្នុង បានឆ្លុះបញ្ចាំងនូវបទដ្ឋានអន្តរជាតិដែលត្រូវបានទទួលស្គាល់ជាទូទៅនៅក្នុងចំណុចនេះ។ ការឆ្លុះបញ្ចាំងទាំងនេះ បង្ហាញថាចម្លើយដែលត្រូវបានធ្វើឡើងនៅក្នុងអំឡុងពេលស៊ើបសួរ អាចត្រូវបានពិចារណាថាអាចជឿជាក់បាន តែក្នុងករណីដែលចម្លើយនោះត្រូវបានផ្តល់ដោយស្ម័គ្រចិត្ត និងគ្មានការបង្ខិតបង្ខំតែប៉ុណ្ណោះ។ ការបដិសេធមិនទទួលយកគឺជាដំណោះស្រាយទូទៅ នៅពេលដែលការរំលោភបំពានសិទ្ធិទាំងនេះត្រូវបានចង្អុលបង្ហាញ[32]។

---

ដើមបណ្តឹងរដ្ឋប្បវេណី (ក្រុម៣) ពាក់ព័ន្ធនឹងកិច្ចសម្ភាសន៍ជនជាប់ចោទដោយលោក PRESCHOUX", ឯកសារលេខ E43, ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០០៩; "សំណើរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ សុំបដិសេធសំណើសុំមិនឲ្យប្រើបទសម្ភាសន៍របស់ CHRISTOPHE PESCHOUX", ឯកសារលេខ E43/1, ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០០៩, ទំព័រទី4។

[31] ប្រតិចារឹកចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៩ ទំព័រទី44, 55, 64-65។

[32] *សូមមើលឧទាហរណ៍* មាត្រា១៤(៣) អនុសន្ធិសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ (ICCPR); មាត្រា៦ នៃសន្ធិសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (ECHR); រឿងក្តី *Murray* តទល់ *United Kingdom*, ECHR (1996) 18731/91, កថាខណ្ឌ45, រឿងក្តី *Saunders* តទល់ *UK*, ECHR (1996) 19187/91, កថាខណ្ឌ68; រឿងក្តី *Shabelnik* តទល់ *Ukraine,* ECHR (2009), 16404/03, កថាខណ្ឌ54-59។ យុត្តិសាស្ត្ររបស់ ICTY និង ICTR តម្កល់បទបញ្ញត្តិសំខាន់ នៃសិទ្ធិទទួលបានការកាត់សេចក្តីដោយយុត្តិធម៌ ដូចដែលមានចែងក្នុងបទបញ្ញត្តិទាំងនេះនៃ ICCPR និង ECHR: *សូមមើលជាឧទាហរណ៍ រឿងក្តីរដ្ឋអាជ្ញា* តទល់ *Mucic និងអ្នកផ្សេងទៀត,* IT-96—21-T, "សេចក្តីសម្រេចញត្តិរបស់ Zdravko Mucis ចំពោះការបដិសេធភស្តុតាង", ចុះថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៩៧, កថាខណ្ឌ៤១; *រឿងក្តីរដ្ឋអាជ្ញា* តទល់ *Bagosora*, សំណុំរឿងលេខ ICTR-98-41-T, "សេចក្តីសម្រេចលើញត្តិរបស់សហព្រះរាជអាជ្ញា ចំពោះការទទួលយកនៃវត្ថុតាងដាក់លាក់ក្រោមវិធាន៨៩ (គ)", ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០០៤, កថា ខណ្ឌ២១; *រឿងក្តីរដ្ឋអាជ្ញា* តទល់ *Halitović*, សំណុំរឿងលេខ IT-01-48-AR73.2, "សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ចាត់របៀបទាក់ទងនឹងការទទួលយកកំណត់ហេតុនៃបទសម្ភាសន៍របស់ជនជាប់ចោទពីតារាងបញ្ជី", ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៥, កថាខណ្ឌទី១៥។

00332884



២០. ដើម្បីបំភ្លឺអំពីកាលៈទេសៈជុំវិញការសួរយកចម្លើយ របស់ឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិលើជនជាប់ចោទ វានឹងជាការចាំបាច់ដែលអង្គជំនុំជម្រះត្រូវស្តាប់អ្នកទាំងអស់គ្នា ដែលមានវត្តមាននៅពេលធ្វើការសួរយកចម្លើយនោះ ហើយជាពិសេស គឺអ្នកតំណាងឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិតែម្តង។ អង្គជំនុំជម្រះបដិសេធមិនទទួលយកចម្លើយនេះ ដោយសំអាងថា ការស៊ើបសួរបន្ថែមដែលចាំបាច់ដើម្បីវាយតម្លៃបានអំពីសុពលភាពនៃការអះអាងរបស់ជនជាប់ចោទ និងដែលចាំបាច់ដល់ការវាយតម្លៃអំពីភាពត្រឹមត្រូវនៃប្រតិចារឹកដែលនឹងរួមបញ្ចូលទាំងការស្តាប់សាក្សីមួយចំនួន ការពិនិត្យលើកាសែតថតសម្លេងព្រមទាំងសំណើសុំឱ្យមានប្រតិចារឹកដែលបានពិនិត្យឡើងវិញរួចនិងការបកប្រែឯកសារថ្មីៗដែលការណ៍នេះនឹងនាំឱ្យមានការពន្យារ ពេលសវនាការយ៉ាងច្រើន។ អង្គជំនុំជម្រះសូមបង្ហាញវិធាន ៨៧(៣)(ខ) ដែលអនុញ្ញាតឱ្យបដិសេធភស្តុតាងដែលមិនអាចទទួលបាននៅក្នុងរយៈពេលមួយសមស្រប។ លើសពីនេះទៅទៀត អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ការសួរយកចម្លើយជនជាប់ចោទផ្សេងៗទៀតជាច្រើន មាននៅក្នុងសំណុំរឿងរួចទៅហើយ ឬក៏ត្រូវបានរៀបចំ នៅពេលសវនាការកាលពីពេលមុនរួចមកហើយ។ ខ្លឹមសារនៃចម្លើយដែលត្រូវបានតវ៉ាជាច្រើនមានលក្ខណៈច្រំដែលលើផ្នែកសារធាតុ ដូច្នេះ ហើយហាក់ដូចជាមានផលប៉ះពាល់តិចតួចណាស់ដល់ការជំនុំជម្រះ។ ដូចនេះ អង្គជំនុំជម្រះមិនបដិសេធ ចម្លើយនេះជាទូទៅនោះទេ ឬក៏បង្គាប់ឱ្យដកចម្លើយនេះចេញពីសំណុំរឿងនោះទេ។ ប៉ុន្តែ អង្គជំនុំជម្រះបដិសេធមិនយកមកប្រើប្រាស់នូវចម្លើយនេះនៅក្នុងរឿងក្តីនេះទេ ដោយសារតែចម្លើយនេះគឺភស្តុតាងដែលមិនអាចទទួលបានក្នុងរយៈពេលសមស្រប និងមានលក្ខណៈច្រំដែល តាមអត្ថន័យនៃវិធាន ៨៧(៣)(ក) និង(ខ)។

*iii. របាយការណ៍អំពី* ឈឹន *សុទ្ធី*

២១. របាយការណ៍អំពី ឈឹន សុទ្ធី មានព័ត៌មានអំពីការឃុំខ្លួនជនរងគ្រោះ នៅមន្ទីរម១៣។ ក.ស.ច.ស មិនអាចរកសាក្សីដែលជាអ្នកផ្តល់ចម្លើយ សម្រាប់សរសេររបាយការណ៍នេះ

ឃើញទេ[33]។ សហព្រះរាជអាជ្ញាបានស្នើសុំអនុញ្ញាតប្រើប្រាស់របាយការណ៍នេះទាក់ទិននឹងការសួរសំណួរបន្ថែមពាក់ព័ន្ធនឹងមន្ទីរ ម១៣។ មេធាវីការពារក្តីមិនបានជំទាស់ទៅនឹងការប្រើប្រាស់របាយការណ៍នេះទេ ប៉ុន្តែមេធាវីការពារក្តីបានស្នើសុំឲ្យមានការបកប្រែឯកសារដើមដល់ខ្លួនប៉ុណ្ណោះ[34]។ អង្គជំនុំជម្រះអនុញ្ញាតឲ្យមានការរៀបចំរបាយការណ៍នេះ។ តម្លៃដាក់បន្ទុកនៃភស្តុតាងនេះ និងការថ្លឹងថ្លែងដើម្បីឲ្យមានការយល់ស្របអំពីរបាយការណ៍នេះ នឹងត្រូវបានវាយតម្លៃដោយអង្គជំនុំជម្រះ តាមពេលកំណត់។

**ផ្អែកតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះសាលាដំបូងសម្រេច:**

**យល់ព្រមតាម** សំណើសុំរបស់សហមេធាវីការពារក្តី ពាក់ព័ន្ធទៅនឹងចម្លើយរបស់សាក្សីដែលបានទទួលមរណភាព គឺ អត្ថបទរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា និងការយកចម្លើយដែលធ្វើឡើងដោយឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ហើយបដិសេធមិនទទួលយកឯកសារទាំងនេះមកធ្វើជាភស្តុតាងនៅក្នុងសវនាការនេះទេ អនុលោមតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។

**យល់ព្រមតាម** សំណើរបស់ការិយាល័យសហព្រះរាជអាជ្ញា ពាក់ព័ន្ធនឹងរបាយការណ៍អំពី ឈឹន សុទ្ធី ព្រមទាំងអនុញ្ញាតឲ្យលើកយករបាយការណ៍នេះមកដេញដោលនៅចំពោះមុខអង្គជំនុំជម្រះដែលជាកម្មវត្ថុនៃការត្រួតពិនិត្យ ដោយយោងតាមវិធាន ៨៧(២) នៃវិធានផ្ទៃក្នុង។

**បង្គាប់** ឲ្យការិយាល័យសហព្រះរាជអាជ្ញាផ្តល់ជូនមេធាវីការពារជនជាប់ចោទ នូវសំណៅបកប្រែដើមនៃរបាយការណ៍អំពី ឈឹន សុទ្ធី នេះ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែឧសភា ឆ្នាំ២០០៨

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**និល - ណុន**

[33] T., ថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៨ ទំព័រ ៧៦-៧៧។

[34] T., ថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៨ ទំព័រ ៤, ១៥-១៦។